# គណៈកម្មការទន្លេមេគង្គ

**ការិយាល័យលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គនៅភ្នំពេញ**
ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម
ប្រអប់សំបុត្រលេខ ៦២៣ ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៨៥៥-២៣ ៤២៥ ៣៥៣.
ទូរសារលេខ ៨៥៥-២៣ ៤២៥ ៣៦៣

**ការិយាល័យលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គនៅវៀងច័ន្ទ**
ការិយាល័យប្រធានលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គ
អគារលេខ ១៨៤ ផ្លូវហ្វា ងុម សាធារណៈរដ្ឋប្រជាធិបតេយ្យ
ប្រជាមានិតឡាវ  ប្រអប់សំបុត្រលេខ ៦១០១ ទីក្រុងវៀងច័ន្ទ ០១០០០
ទូរស័ព្ទលេខ ៨៥៦-២១ ២៦៣ ២៦៣
ទូរសារលេខ ៨៥៦-២១ ២៦៣ ២៦៤


## សំណួរដែលលើកឡើងជាញឹកញាប់

## <u>នីតិវិធីរបស់គណៈកម្មការទន្លេមេគង្គសម្រាប់នីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង</u>

**<u>(PNPCA)</u>**

នៅចុងខែកញ្ញា ឆ្នាំ 2010 គណៈកម្មការទន្លេមេគង្គ (MRC) បានទទួលជាផ្លូវការពីរដ្ឋាភិបាលឡាវ នូវឯកសារសំណើគម្រោងអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គ។ ទោះបីព័ត៏មានដំបូងស្តីពីគម្រោងនេះត្រូវបានចែកជូនក្នុងចំណោមប្រទេសជាសមាជិកនៃ គណៈកម្មការទន្លេមេគង្គជាមុនរួចមកហើយក៏ដោយ ការដាក់ជូនឯកសារជាផ្លូវការបែបនេះជាលើកដំបូង បានជម្រុញឱ្យមានការបង្កើតនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ សម្រាប់នីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA)។

*ហេតុអ្វីប្រទេសជាសមាជិក គណៈកម្មការទន្លេមេគង្គតម្រូវឱ្យមានការពិគ្រោះយោបល់ មុននឹងកសាងផែនការអភិវឌ្ឍន៍លើទន្លេមេនៃទន្លេមេគង្គ?*

យោងតាមកិច្ចព្រមព្រៀងទន្លេមេគង្គ ឆ្នាំ 1995 ដែលបានបង្កើតគណៈកម្មការទន្លេមេគង្គ ប្រទេសជាសមាជិកត្រូវតែចាត់ចែងឱ្យមានការពិគ្រោះយោបល់ជាមុន ដើម្បីពិភាក្សាអំពីផលប៉ះពាល់ឆ្លងដែន ដែលការអភិវឌ្ឍនៅលើទន្លេមេនៃទន្លេមេគង្គអាចបង្កមកលើប្រទេសនៅជិតខាង មុននឹងធ្វើការសម្រេចបន្តជំហាននៃការអភិវឌ្ឍនោះ។ ដំណើរការពិគ្រោះយោបល់នេះ មានគោលដៅទប់ស្កាត់ឥទ្ធិពលអវិជ្ជមានមកលើសហគមន៍តាមដងទន្លេ និងបរិស្ថាននៅក្នុងតំបន់ខ្សែទឹកខាងក្រោម។

*ហេតុអ្វីគម្រោងថាមពលវារីអគ្គិសនីពីមុនមក ពុំតម្រូវឱ្យធ្វើការពិគ្រោះយោបល់មុននឹងអភិវឌ្ឍន៍? តើអ្វីខ្លះជាភាពខុសគ្នារវាងការជូនដំណឹងអំពីទំនប់នៅលើដៃទន្លេណាមួយនិងនីតិវិធីនៃការពិគ្រោះយោបល់ជាមុនសម្រាប់សំណើអភិវឌ្ឍន៍នៅលើទន្លេមេនៃទន្លេមេគង្គ?*

មុនមានសំណើគម្រោងសាយ៉ាប៊ូរី គម្រោងថាមពលវារីអគ្គិសនីនានាត្រូវបានកសាងឡើងនៅលើដៃនានានៃទន្លេមេគង្គតែប៉ុណ្ណោះ ប៉ុន្តែមិនមែននៅលើទន្លេមេនៃទន្លេមេគង្គឡើយ។ ភាពខុសគ្នារវាងការអភិវឌ្ឍនៅលើដៃទន្លេ និងលើទន្លេមេនៃទន្លេមេគង្គ ស្ថិតនៅត្រង់ថាសំណើ គម្រោងនៅលើដៃទន្លេនានាត្រូវផ្តល់ត្រឹមការជូនដំណឹងទៅប្រទេសដទៃទៀតដែលជាសមាជិកនៃគណៈកម្មការទន្លេមេគង្គ ចំណែកការអភិវឌ្ឍនៅលើទន្លេមេនៃទន្លេមេគង្គ ដែលត្រូវបានចាត់ទុកថាមានសក្តានុពលក្នុងការបង្កផលប៉ះពាល់ឆ្លងដែនកាន់តែច្រើន តម្រូវឱ្យមាន

ការពិគ្រោះយោបល់ជាមុន ដើម្បីឱ្យប្រទេសជាសមាជិក អាចធ្វើការពិនិត្យដោយហ្មត់ចត់លើគម្រោងនោះ ក្នុងគោលដៅឈានដល់កិច្ចព្រមព្រៀងមួយថាតើត្រូវបន្តអនុវត្តគម្រោងនោះដែរឬទេ ហើយប្រសិនបើត្រូវបន្តអនុវត្ត តើត្រូវធ្វើនៅក្រោមលក្ខខណ្ឌណាខ្លះ។

*តើការអភិវឌ្ឍថាមពលវារីអគ្គិសនីគឺជាការអភិវឌ្ឍតែមួយបែបនៅលើទន្លេមេនៃទន្លេមេគង្គ ដែលទាមទារឱ្យមានការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងអំពីវិធីដែលត្រូវអនុវត្តបន្តឬយ៉ាងណា?*

រាល់សំណើអភិវឌ្ឍន៍នៅលើទន្លេមេនៃទន្លេមេគង្គ ត្រូវតែឆ្លងកាត់នីតិវិធីនៃការពិគ្រោះយោបល់ជាមុន និងមានគោលដៅឈានឱ្យដល់កិច្ចព្រមព្រៀងរួមគ្នាមួយលើវិធីដែលត្រូវបន្តអនុវត្ត។ ឧទាហរណ៍ គម្រោងបង្វែរទឹកពីទន្លេមេនៃទន្លេមេគង្គ ក៏ត្រូវតែមានការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងគ្នាក្នុងចំណោមប្រទេសជាសមាជិកនៃគណៈកម្មការទន្លេមេគង្គផងដែរ ប្រសិនបើគម្រោងបង្វែរទឹកនោះ ទាក់ទងជាមួយការប្រើប្រាស់ទឹកពីទន្លេមេគង្គ សម្រាប់បញ្ចូលទៅក្នុងអាងទន្លេមួយផ្សេងទៀត។

*តើនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង គឺជាអ្វី?*

នីតិវិធីនៃការពិគ្រោះយោបល់ជាមុន នៅក្រោមនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង គឺជាលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ 1995 សម្រាប់ប្រទេសនានា ដើម្បីធ្វើការពិនិត្យរួមគ្នាលើសំណើគម្រោងអភិវឌ្ឍន៍ណាមួយនៅលើទន្លេមេនៃទន្លេមេគង្គ ក្នុងគោលបំណងឈានដល់ការឯកភាពមតិមួយ អំពីថាតើគួរតែបន្តអនុវត្តឬយ៉ាងណា ហើយប្រសិនបើត្រូវបន្តអនុវត្ត តើត្រូវធ្វើនៅក្រោមលក្ខខណ្ឌណាខ្លះ។

គោលបំណងធំជាងនេះនៃនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង គឺធ្វើឱ្យប្រទេសដែលជាអ្នកលើកសំណើអភិវឌ្ឍន៍នៅលើទន្លេមេនៃទន្លេមេគង្គ ពិនិត្យយ៉ាងហ្មត់ចត់ មុននឹងអនុញ្ញាតឱ្យគម្រោងនេះអនុវត្តជាបន្ត។ ផលប៉ះពាល់ឆ្លងដែនបណ្តាលពីគម្រោងនៅលើទន្លេមេនៃទន្លេមេគង្គ ត្រូវបានចាត់ទុកថាជាឥទ្ធិពលដែលមានទំហំធំជាងគម្រោងនានានៅលើដៃទន្លេ ដូច្នេះទាមទារឱ្យមានការពិគ្រោះយោបល់កាន់តែហ្មត់ចត់ និងការឯកភាពមតិមួយ ក្នុងចំណោមប្រទេសជាសមាជិកទាំងបួន។

តើមានជំហានអ្វីខ្លះដែលត្រូវអនុវត្ត មុននឹងប្រទេសជាសមាជិកសម្រេចអំពីវិធីដែលត្រូវបន្តអនុវត្ត?

១. ការដាក់ជូនសំណើ: ដំណើរការដែលចាប់ផ្តើមជាផ្លូវការ នៅពេលដែលគណៈកម្មការទន្លេមេគង្គ ទទួលឯកសារដាក់ជូនពីស្ថាប័នពាក់ព័ន្ធនៃរដ្ឋាភិបាលនៃប្រទេសដែលលើកសំណើអភិវឌ្ឍន៍នៅលើដងទន្លេមេគង្គ តាមរយៈគណៈកម្មាធិការជាតិនៃប្រទេសនោះ។ ក្រោយការពិនិត្យលើកម្រិតនៃការគោរពតាមលក្ខខណ្ឌនៃការចងក្រងជាឯកសារ លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ បញ្ជូនឯកសារនោះទៅបណ្តាប្រទេសបីផ្សេងទៀតដែលជាសមាជិក តាមរយៈសមាជិកគណៈកម្មាធិការរួម (Joint Committee of the MRC) របស់ប្រទេសទាំងនោះ។

២. ការវាយតម្លៃ: នៅពេលដែលប្រទេសជាសមាជិកទាំងអស់បានទទួលឯកសារដែលផ្ញើជូននោះហើយ ដំណើរការមួយនៃការពិនិត្យបច្ចេកទេសនឹងត្រូវចាប់ផ្តើម និងសម្របសម្រួលដោយលេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ។ ប្រទេសទាំងនោះ នឹងធ្វើការពិគ្រោះយោបល់រួមគ្នា លើសំណើអភិវឌ្ឍន៍នៅលើទន្លេមេនៃទន្លេមេគង្គ និងស្នើសុំព័ត៌មានបន្ថែមទៀត តាមការចាំបាច់។ ការពិនិត្យនេះ នឹងកំណត់អំពីកម្រិតនៃការគោរពតាមនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ ស្តីពីរបបធារទឹក និងវិស័យសំខាន់ៗដែលរងការប៉ះពាល់ខាងផ្នែកបរិស្ថាន និងសង្គម ដែលរួមទាំងវិសាលភាពនៃផលប៉ះពាល់ឆ្លងដែនណាមួយ ដែលត្រូវបានដោះស្រាយបានគ្រប់គ្រាន់ផងដែរ។

៣. ការឈានដល់កិច្ចព្រមព្រៀង: ក្រោយការពិគ្រោះយោបល់ គោលដៅគឺត្រូវឈានឱ្យដល់កិច្ចព្រមព្រៀងរួមមួយ ក្នុងចំណោមសមាជិកគណៈកម្មាធិការរួមរបស់គណៈកម្មការទន្លេមេគង្គលើវិធីដែលត្រូវបន្តអនុវត្ត។ គោលដៅរបស់គណៈកម្មការទន្លេមេគង្គ

គឺជួយប្រទេសជាសមាជិក ក្នុងការស្វែងរកដំណោះស្រាយប្រកបដោយនិរន្តរភាពសម្រាប់ទន្លេនេះ និងប្រជាពលរដ្ឋរបស់ខ្លួននៅក្នុងអំឡុងពេលនៃដំណើរការនេះ។

*តើនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង ត្រូវការរយៈពេលប៉ុន្មាន?*

នីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង ចាប់ផ្តើមជាផ្លូវការនៅថ្ងៃដែលសមាជិកគណៈកម្មាធិការរួមចុងក្រោយ បានទទួលឯកសារដាក់ជូននេះ ពីលេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ។ ចាប់ផ្តើមពីចំណុចនេះរហូតដល់ការសម្រេចចុងក្រោយដំណើរការពិគ្រោះយោបល់ អាចចំណាយពេល 6 ខែ ប៉ុន្តែ អាចពន្យាពេលជាបន្ត ប្រសិនបើចាំបាច់។

*តើអ្នកណាខ្លះនឹងត្រូវចូលរួមពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង?*

សមាជិកគណៈកម្មាធិការរួមនេះ នឹងចាត់តាំងតំណាងរហូតដល់បួនរូបមកពីប្រទេសនីមួយៗទាំងនេះ ដើម្បីឱ្យជួយនៅក្នុងនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងនេះ ដែលជាផ្នែកមួយនៃក្រុមការងារមួយ។ លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ ក៏នឹងជ្រើសរើសតំណាងមួយរូបមកពីកម្មវិធីស្នូលនីមួយៗ ឱ្យចូលរួមនៅក្នុងក្រុមការងារផ្ទៃក្នុងស្តីពីនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង របស់ពួកគេផងដែរ។

*តើគណៈកម្មការទន្លេមេគង្គ មានតួនាទីអ្វីខ្លះនៅក្នុងនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងនេះ?*

គណៈកម្មការទន្លេមេគង្គ មានតួនាទីផ្តល់យោបល់លើហានិភ័យ និងឱកាសពីសំណើគម្រោង និងក្នុងការសម្រួលឱ្យមានទស្សនៈរួមសម្រាប់ការអភិវឌ្ឍអាងទន្លេមេគង្គ ដែលកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា នូវឥទ្ធិពលអវិជ្ជមាន និងទំហំនៃទំនាស់។

ចាប់ពីឆ្នាំ 1995 មក គណៈកម្មការទន្លេមេគង្គបាន និងកំពុងក្លាយជា*ស្ថាប័នផ្តល់យោបល់អន្តររដ្ឋាភិបាល*។ ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល ដែលកសាងផែនការអភិវឌ្ឍន៍ណាមួយនៅលើទន្លេមេនៃទន្លេមេគង្គ ត្រូវទាក់ទងជាមួយគណៈកម្មការទន្លេមេគង្គ តាមរយៈសមាជិកគណៈកម្មាធិការរួមរបស់ពួកគេរៀងៗខ្លួន និងបន្ទាប់ពីនោះ គណៈកម្មការទន្លេមេគង្គត្រូវធ្វើការជាមួយប្រទេសជាសមាជិក ដើម្បីឈានទៅរកការសម្រេចរួមគ្នាមួយលើរបៀបបន្តអនុវត្ត។

*តើកត្តាអ្វីខ្លះត្រូវយកមកពិចារណា នៅក្នុងអំឡុងពេលវាយតម្លៃនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង?*

នៅក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃ សមាជិកគណៈកម្មាធិការរួម ត្រូវពិចារណាថាតើសំណើអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅលើទន្លេមេនៃទន្លេមេគង្គឆ្លើយតបដែរឬទេទៅនឹងលក្ខខណ្ឌដូចតទៅ:

- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក
- ផ្តល់អត្ថប្រយោជន៍ប្រសើរជាងអ្វីដែលអាចទទួលបាន តាមរយៈកិច្ចសហប្រតិបត្តិការ និងសម្បទាន
- បានកំណត់សិទ្ធិក្នុងការទាមទារ ធៀបនឹងសំណើប្រើប្រាស់ជាបន្ថែម
- វាយតម្លៃផលប៉ះពាល់ដែលអាចកើតមាន មកលើសិទ្ធិ និងផលប្រយោជន៍របស់អ្នកពាក់ព័ន្ធនានា និង
- ផ្តល់សន្តិសុខលើការកសាងផែនការ។

លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គត្រូវធ្វើការពិនិត្យខាងបច្ចេកទេស ធៀបនឹងគោលការណ៍ណែនាំដំបូងសម្រាប់បង្កើតគំរូប្លង់ដែលបានអនុម័ត ឯកភាពដោយគណៈកម្មាធិការរួមរួចមកហើយ។

*តើនីតិវិធីនៃការពិគ្រោះយោបល់ជាមុន រួមបញ្ចូល ទស្សនៈនានារបស់សមគមន៍រងគ្រោះនៅតាមដងទន្លេដែរឬទេ?*

តាមរយៈយន្តការនានាមួយចំនួន ដែលរួមទាំង កម្មវិធីកសាងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គនៃគណៈកម្មការទន្លេមេគង្គ ដំណើរការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការដាក់ជូនតាមរយៈវិបសាយដែលបាន និងកំពុងប្រតិបត្តិការអស់រយៈពេលច្រើនជាងមួយឆ្នាំមកហើយ ទស្សនៈទានរបស់សាធារណជន នឹងត្រូវយកមកពិចារណា នៅក្នុងដំណើរការវាយតម្លៃលើការពិគ្រោះយោបល់ជាមុន។

ជាទូទៅ គណៈកម្មការទន្លេមេគង្គបានចាត់ទុកការចូលរួមជាសាធារណៈ និងការពិគ្រោះយោបល់ ថាជាសមាសធាតុស្នូលនៅក្នុងការប្តេជ្ញារបស់ខ្លួន។ ឧទាហរណ៍ យុទ្ធសាស្ត្រ (ឆ្នាំ 2007-2011) របស់គណៈកម្មការទន្លេមេគង្គ ចែងថា កំណើនការចូលរួមរបស់អ្នកពាក់ព័ន្ធ មានសារៈសំខាន់ណាស់សម្រាប់ការគ្រប់គ្រងអាងទន្លេឱ្យមានប្រសិទ្ធភាព។ លើសពីនេះ ប្រទេសជាសមាជិកបានបង្ហាញពីការប្តេជ្ញារបស់ខ្លួន ក្នុងការធ្វើឱ្យអ្នកពាក់ព័ន្ធបានចូលរួមតាមរយៈការគាំទ្រ និងការអនុវត្តយុទ្ធសាស្ត្រ និងគោលការណ៍គ្រប់គ្រងចម្រុះធនធានទឹករបស់គណៈកម្មការទន្លេមេគង្គ នៅកម្រិតអាងទន្លេ។

អាស្រ័យហេតុនេះ នៅក្នុងករណីដែលការសម្រេចនានាអំពីវិធីក្នុងការបន្តទៅអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គ គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការរួម ទស្សនៈនានារបស់សហគមន៍រងគ្រោះ នឹងត្រូវបង្ហាញជូនតាមរយៈការវាយតម្លៃហេតុប៉ះពាល់ដែលបានធ្វើឡើងពីមុនមក ដូចជា ដំណើរការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ។ ប្រសិនបើគណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គសម្រេចថា ត្រូវការព័ត៌មានជាបន្ថែមទៀតអំពី ទស្សនៈនានារបស់សហគមន៍នៅតាមដងទន្លេ ឬ ប្រសិនបើពុំមានការយល់ដឹងពេញលេញអំពីវិសាលភាពនៃផលប៉ះពាល់មកលើសហគមន៍ពួកគេ អាចស្នើសុំឱ្យធ្វើការពិគ្រោះយោបល់ និងការស្រាវជ្រាវបន្ថែមទៀត។

*តើមានអ្វីកើតឡើង ប្រសិនបើប្រទេសនានាមិនអាចឈានដល់ការសម្រេចរួមមួយនៅក្នុងអំឡុងពេលនៃការអនុវត្តនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង?*

ប្រសិនបើចាំបាច់ គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ អាចបន្តដំណើរការរហូតដល់មានការឯកភាពមតិ។ ប្រសិនបើនៅតែមិនអាចធ្វើបាន ទស្សនៈទាំងនេះត្រូវកត់ត្រាទុក ហើយប្រទេសដែលជាអ្នកជូនដំណឹង ត្រូវយកទស្សនៈទាំងនេះបញ្ចូលទៅក្នុងការពិចារណា នៅពេលឈានដល់ការសម្រេចចុងក្រោយអំពីគម្រោងនោះ។ ប្រសិនបើគណៈកម្មាធិការនេះសម្រេចបន្តអនុវត្តគម្រោង នៅពេលនោះ គណៈកម្មការទន្លេមេគង្គ ត្រូវធ្វើការពិចារណាជាពិសេសលើមាត្រានានានៃកិច្ចព្រមព្រៀងទន្លេមេគង្គ ដែលទាក់ទងនឹងគ្រោះថ្នាក់ដែលអាចកើតចេញពីការប្រើប្រាស់ដែលបានលើកស្នើនោះ។

*តើមានអ្វីកើតឡើង ប្រសិនបើប្រទេសជាសមាជិករំលោភលើនីតិវិធីនេះ?*

ប្រសិនបើប្រទេសជាសមាជិកមួយដឹងថា នីតិវិធីនានាត្រូវបានរំលោភហើយនោះ នៅក្រោមកិច្ចព្រមព្រៀងនេះ មានដំណើរការមួយដែលជួយដោះស្រាយទំនាស់នានា ប្រសិនបើទំនាស់ទាំងនោះកើតឡើង។ គណៈកម្មាធិការរួម និង ក្រុមប្រឹក្សារបស់គណៈកម្មការទន្លេមេគង្គ មានភារៈទទួលបន្ទុកលើកឡើង និងដោះស្រាយទំនាស់នានា ដែលសមាជិកក្រុមប្រឹក្សា សមាជិកគណៈកម្មាធិការរួម ឬ ប្រទេសជាសមាជិកបានដាក់ជូនទៅពួកគេ។

ប្រសិនបើគណៈកម្មាធិការរួម ឬ ក្រុមប្រឹក្សានេះមិនអាចដោះស្រាយភាពខុសគ្នា ឬទំនាស់ឱ្យបានទាន់ពេលវេលាទេនោះ បញ្ហានេះនឹងត្រូវដាក់ជូនទៅរដ្ឋាភិបាលនៃប្រទេសជាសមាជិកធ្វើការដោះស្រាយ ដោយធ្វើការចរចាតាមរយៈមធ្យោបាយការទូត។ រាល់ទំនាស់ក៏អាចដាក់ជូនទៅភាគីទីបី ដើម្បីធ្វើការសម្រុះសម្រួលផងដែរ ក្រោយមានការព្រមព្រៀងជាមួយគ្នា។

*តើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រអំពីគម្រោងថាមពលវារីអគ្គិសនីទាំងដប់ពីរដែលបានគ្រោងឡើង ជាផ្នែកមួយនៃនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងដែរឬទេ?*

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ មិនមែនជាផ្នែកផ្លូវការមួយនៃនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងឡើយ ប៉ុន្តែផ្តល់គំនិតទៅក្នុងដំណើរការនេះ។

សំណើចំនួនដប់ពីរ សម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គ បានតម្រូវឱ្យមានការចាត់ចែងដោយគណៈកម្មការទន្លេមេគង្គ ដើម្បីធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនៅដើមឆ្នាំ 2009។ នៅក្នុងករណីដែលដំណើរការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង គឺជាដំណើរការឯកភាពគ្នាមួយរវាងរដ្ឋាភិបាលនានា ដែលវាយតម្លៃគម្រោងនីមួយៗនៅលើទន្លេមេនៃទន្លេមេគង្គដាច់ដោយឡែកពីគ្នា ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ធ្វើការគិតគូរគ្រប់ជ្រុងជ្រោយអំពីហានិភ័យ ដោយប្រៀបធៀបជាមួយឱកាសសម្រាប់សេណារីយ៉ូទាំងមូលនៃការអភិវឌ្ឍនៅលើទន្លេមេនៃទន្លេមេគង្គ ដែលអាចនាំឱ្យមានការវាយតម្លៃផលប៉ះពាល់សរុប។ អភិក្រមឆ្លងដែននៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ផ្តល់នូវទស្សនៈវិស័យដ៏មានតម្លៃនៅថ្នាក់តំបន់ នៅក្នុងនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង ។

*តើស្តង់ដារអ្វីដែលគណៈកម្មការទន្លេមេគង្គយកមកអនុវត្តនៅក្នុងនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង?*

គណៈកម្មការទន្លេមេគង្គ អនុវត្តស្តង់ដារនានា ដោយគោរពតាមគោលការណ៍នានានៃកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ 1995 ដែលផ្តោតលើការបង្កើនជាអតិបរមានូវផលប្រយោជន៍រវាងគ្នា ការលើកកំពស់និរន្តរភាព និងការថែរក្សាប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ។ គណៈកម្មការទន្លេមេគង្គ បានបម្លែងស្តង់ដារទាំងនេះទៅជានីតិវិធីផ្សេងៗទៀត ដូចជា នីតិវិធីសម្រាប់រក្សាធារទឹកនៅក្នុងទន្លេមេនៃទន្លេមេគង្គ (Procedures for Maintenance of Flows on the Mainstream) នីតិវិធីសំរាប់គុណភាពទឹក (Procedures for Water Quality) និងការណែនាំលើការបង្កើតគំរូប្លង់ដំបូងសម្រាប់ទំនប់នានានៅលើទន្លេមេនៃ ទន្លេមេគង្គភាគក្រោម។ នីតិវិធីទាំងនេះ ផ្តល់ឱ្យប្រទេសជាសមាជិក និងក្រុមហ៊ុនអភិវឌ្ឍន៍នូវការចង្អុលបង្ហាញអំពីស្តង់ដារនានា ដែលនឹងត្រូវយកមកពិចារណានៅក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃ នីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង។ នៅពេលថ្មីៗនេះ គណៈកម្មការទន្លេមេគង្គ ក៏បានអនុម័តលើឯកសារណែនាំសម្រាប់ការបង្កើតគំរូប្លង់ដំបូង សម្រាប់វិស័យសំខាន់ៗចំនួនប្រាំផងដែរ ពោលគឺចរាចរធនធានជលផល គុណភាពទឹក ការគ្រប់គ្រងកំទេចកំណកសេរីភាពក្នុងការធ្វើនាវាចរ និងសុវត្ថិភាពទំនប់។

*ហេតុអ្វីទើបដំណើរការនេះត្រូវបានផ្តួចផ្តើមឡើង នៅពេលដែលមានការសង្ស័យអំពីផលប៉ះពាល់នៃគម្រោងនៅលើទន្លេមេនៃទន្លេមេគង្គ?*

ការទទួលខុសត្រូវលើការជម្រុញឱ្យមាននីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង គឺជារបស់ប្រទេសសមាជិកដែលលើកស្នើគម្រោងនេះ។ នៅពេលបានជូនដំណឹងហើយ គណៈកម្មការទន្លេមេគង្គត្រូវធ្វើការឆ្លើយតប ស្របតាមលក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គ។ មនុស្សជាច្រើនបានអះអាងថា ដំណើរការនេះគួរ តែធ្វើឡើងនៅក្នុងដំណាក់កាលដើមដំបូងបំផុតតាមតែអាចធ្វើបាននៅក្នុងវដ្តនៃការកសាងផែនការ ដើម្បីផ្តល់យោបល់តបទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍អំពីជាបញ្ហាគន្លឹះ ដែលពួកគេនៅមានកង្វល់ថា លទ្ធភាពក្នុងការកែតម្រូវអាចថយចុះ។

*តើនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង មិនមែនគ្រាន់តែជាលំហាត់មួយទេឬយ៉ាងណា?*

ប្រទេសជាសមាជិកនៃគណៈកម្មការទន្លេមេគង្គ បានទទួលស្គាល់អំពីភាពចាំបាច់ឱ្យអនុវត្តនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងដោយហ្មត់ចត់។ នៅឆ្នាំ 1995 ប្រទេសជាសមាជិកទាំងបួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទន្លេមេគង្គ ដែលតម្រូវឱ្យមាននីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង នៅក្នុងករណីដែលមានការអភិវឌ្ឍចំបងៗនៅ លើទន្លេមេនៃទន្លេមេគង្គ។ ចាប់តាំងពីពេលនោះមក គោលការណ៍ណែនាំនានាត្រូវបានរៀបចំឡើង ដើម្បីណែនាំដល់ការអនុវត្តពិស្តារ។ ប្រការសំខាន់គឺត្រូវកត់ សំគាល់ផងដែរថា រាល់ការអភិវឌ្ឍនៅលើទន្លេមេនៃទន្លេមេគង្គ ទំនងជាមានឥទ្ធិពលមកលើប្រទេសជាសមាជិកទាំងអស់នៅតាមទន្លេមេនៃទន្លេមេគង្គ អាស្រ័យហេតុនេះ ទាមទារឱ្យមានការសម្រេចរួមមួយអំពីវិធីដែលត្រូវអនុវត្តជាបន្ត។

មេដឹកនាំរដ្ឋាភិបាលនៃប្រទេសទាំងបួនបានអះអាងឡើងវិញនូវកិច្ចសហប្រតិបត្តិការពេញលេញ លើការអនុវត្តកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ 1995 នៅពេលដែលប្រទេសទាំងនោះជួបគ្នានៅក្នុងកិច្ចប្រជុំកំពូលលើដំបូងរបស់គណៈកម្មការទន្លេមេគង្គ នៅខែ មេសា ឆ្នាំ 2010។

*តើលទ្ធផលដែលបានឯកភាពគ្នាពីនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងមួយ មានឥទ្ធិពលមកលើសំណើអភិវឌ្ឍន៍នៅលើទន្លេមេនៃទន្លេមេគង្គទៅអនាគតក្នុងការជម្រុញឱ្យមានដំណើរការដូចគ្នានេះដែរឬទេ?*

នៅពេលដែលគម្រោងថាមពលវារីអគ្គិសនីដាក់ជូនសំណើរបស់ខ្លួនទៅគណៈកម្មការទន្លេមេគង្គ ដាច់ដោយឡែកពីគ្នា គណៈកម្មាធិការរួមក៏ត្រូវតែធ្វើការវាយតម្លៃលើឯកសារដែលជូនបែបនេះម្តងមួយៗដែរ ប៉ុន្តែនៅក្នុងក្របខ័ណ្ឌនៃរូបភាពអំពីផលប៉ះពាល់រួម ដែលបង្ហាញដោយការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ។ នៅពេលដែលប្រទេសជាសមាជិកឈានដល់ការសម្រេចជាចុងក្រោយអំពីវិធីដើម្បីបន្តអនុវត្តសំណើអភិវឌ្ឍន៍មួយនៅលើទន្លេមេនៃទន្លេមេគង្គ ប្រសិនបើប្រទេសទាំងនោះសម្រេចថា ត្រូវបន្តអនុវត្តគម្រោងអភិវឌ្ឍន៍នោះ ការសម្រេចនានាគួរតែយកមកអនុវត្តសម្រាប់តែគម្រោងជាក់លាក់មួយនោះតែប៉ុណ្ណោះ។ នៅក្នុងករណីដែលគម្រោងថាមពលវារីអគ្គិសនីទៅអនាគតត្រូវបានដាក់ជូនទៅគណៈកម្មការទន្លេមេគង្គ សម្រាប់ដំណើរការពិគ្រោះយោបល់ជាមុន នៅពេលនោះគេត្រូវធ្វើការវាយតម្លៃគម្រោងនោះ ដោយផ្អែកលើសំណើផ្ទាល់របស់ខ្លួន ធៀបនឹងហានិភ័យ ឱកាស និងផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គម ដែលគម្រោងនោះអាចបង្កមកលើទន្លេមេគង្គ និងប្រជាជននៅលើដងទន្លេនេះ។